# ប្រាសាទភ្នំព្រះនេត្រព្រះ

ប្រាសាទភ្នំព្រះនេត្រព្រះមានទីតាំងឋិតនៅលើភ្នំតូចមួយឈ្មោះ ភ្នំព្រះនេត្រព្រះ ក្នុងឃុំជប់វារី ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ ភ្នំនេះស្ថិតនៅដាច់តែឯងក្បែរវាលទំនាបទបន្លេសាបផ្នែកខាងពាយ័ព្យ។ បើយើងពិនិត្យ ឬសង្កេតមើលពីចម្ងាយតាមទិសណាមួយ យើងឃើញថា ភ្នំនេះមានទម្រង់ដូចជាគ្រាប់ភ្នែកមួយ លេចធ្លោឡើងពីទំនាបវាលស្រែដ៏វែង ហេតុដូចនេះហើយទើបអ្នកស្រុកហៅថាភ្នំព្រះនេត្រព្រះ។ ប៉ុន្តែនេះជាឈ្មោះដែលអាចនឹងកើតឡើងនាសម័យក្រោយ ឬសម័យកណ្តាល ហើយឈ្មោះដើមរបស់ភ្នំនេះនៅមិនទាន់មានការយល់ស្របរបស់អ្នកស្រាវជ្រាវនៅឡើយទេ ត្បិតមានសិលាចារឹកមួយចំនួនបាននិយាយរៀបរាប់អំពីការស្ថាបនាប្រាសាទនៅលើខ្នងភ្នំនេះ។

លោក ឡាហ្សុងគ្គីយ៉េ បានទៅដល់ និងចុះបញ្ជីប្រាសាទនេះក្នុងលំដាប់លេខរៀងទី ៨២១[១] និងបានគូសប្លង់ប្រាសាទដែលអាចឃើញពីទ្រង់ទ្រាយដើមបាន ប៉ុន្តែសព្វថ្ងៃប្រាសាទនេះបានរលំបាក់អស់ និងមានការបំផ្លាញដោយសារសង្គ្រាម ការជីកកាយរកវត្ថុបុរាណ និងការសាងសង់សំណង់ពុទ្ធសាសនាថ្មីពីលើ ជាហេតុធ្វើឱ្យយើងពិបាកក្នុងការសម្រង់ប្លង់ដើមរបស់ប្រាសាទនេះឡើងវិញណាស់។

### របនាសម្ព័ន្ធទូទៅនៃសំណង់

ប្រាសាទនេះសង់នៅលើកំពូលភ្នំផ្នែកខាងត្បូង មានស្នាកស្នាមកំពែង និងក្លោងទ្វារនៅផ្នែកខាងកើត (សព្វថ្ងៃស្ទើបាត់អស់ហើយ) និងប្រាង្គកណ្តាលមួយ ធ្វើអំពីឥដ្ឋ មានស៊ុំទ្វារធ្វើអំពីថ្មភក់ពណ៌លឿង និងផ្តាឈូក បែរមុខទៅទិសខាងកើត ភ្ជាប់ដោយសំណង់លយ (មណ្ឌប) ដែលមានស៊ុំទ្វារនិងបង្អួចធ្វើអំពីថ្មភក់។ សំណង់ដើមទាំងមូលរបស់ប្រាសាទនេះអាចធ្វើអំពីឥដ្ឋភាគច្រើន និងថ្មភក់សម្រាប់ទ្វារ បង្អួច សសរពេជ្រ និងផ្តែរ។ នៅសម័យសង្គ្រាម នៅចំកណ្តាលសំណង់មណ្ឌប ជាទីតាំងដំឡើងកាំភ្លើងធំសម្រាប់ប្រយុទ្ធ បានធ្វើឱ្យខ្ទេច និងរលំប្រាសាទ ជញ្ជាំងស្ទើទាំងស្រុង ជាហេតុធ្វើឱ្យយើងមិនអាចមើលឃើញពីទ្រង់ទ្រាយដើមទាំងស្រុងរបស់ប្រាសាទនេះបាន។ តាមរយៈគំនូរប្លង់របស់

---

[១] E. Lunet de Lajonquière 1911:417

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

*លោកឡាហ្សង់ហ្គីយ៉ា (រូបលេខ១)[២] លោកបានបែងចែករចនាសម្ព័ន្ធរបស់ប្រាសាទនេះ គឺមានប្រាង្គ(A) ជាប្រាង្គតូច១មួយនៅខាងជើង(B) ជាប្រាង្គកណ្តាល(C) ជាបន្ទប់ធំបន្តពីមុខប្រាង្គកណ្តាល និង(D)ជាបន្ទប់គោបុរ:ខាងកើត។ តាមស្ថានភាពជាក់ស្តែង ប្រាសាទនេះនៅមិនទាន់បានស្ថាបនារួចរាល់ជាស្ថាពរទេ ព្រោះគ្រឿងលម្អស្ថាបត្យកម្មភាគច្រើននៅធ្វើទាន់រួចនៅឡើយ(រូបលេខ២-៣)។*

## *កាលបរិច្ឆេទនៃការសាងសង់*

*តាមរយៈសិលាចារឹកចំនួន៣[៣] ដែលគេបានជួបប្រទះនៅប្រាសាទភ្នំព្រះនេត្រព្រះនេះ អាចឱ្យគេសិក្សាបានអំពីដំណើរការនៃការស្ថាបនាប្រាសាទនេះ។ ក្រោយមក លោកសឺដេស[៤] បានចុះបញ្ជីសិលាចារឹកទាំងនោះ គឺ K.215 (មាន១៨បន្ទាត់) ជាសិលាចារឹកនៅសុំទ្វារខាងកើត (ផ្ទៃខាងត្បូង) របស់ប្រាង្គធំកណ្តាល (ប្រាង្គB) (រូបលេខ៤) និង K.216 ជាសិលាចារឹកនៅលើសុំទ្វាររបស់អគារ (C) ខាងមុខប្រាង្គកណ្តាល (មាន២ផ្ទាំង ដែលផ្ទាំងទី១មាន៥១បន្ទាត់ និងផ្ទាំងទី២មាន១៩បន្ទាត់)។ សិលាចារឹកទាំង៣ផ្ទាំងមានកាលបរិច្ឆេទផ្សេងៗគ្នា និងនិយាយអំពីព្រឹត្តិការណ៍ផ្សេងគ្នាដែរ។ សិលាចារឹក K.215 អាចត្រូវបានចារក្នុងឆ្នាំ ៨៧១ស.ក (៩៤៩គ.ស) រំលឹកអំពីរឿងរ៉ាវនៃការចាប់ផ្តើមសាងសង់ប្រាសាទនេះ (អាស្រម) ក្នុងឆ្នាំ ៨៦០ស.ក (៩៣៨គ.ស) ដោយបុគ្គលម្នាក់ឈ្មោះ **លោញ អប** នៅឯ **ព្រៃតំរ៉ង** (ព្រៃដំបង)។ តែក្រោយមក ក្នុងឆ្នាំ ៨៧១ស.ក (៩៤៩គ.ស) **លោញ អប** បានស្លាប់បាត់ ហើយការសាងសង់ប្រាសាទនោះត្រូវបានបញ្ឈប់បុផ្អាក ហើយមានស្ត្រីឈ្មោះ **ហៀង** ត្រូវជាក្មួយខាងម្តាយ រួមនិងមនុស្សជាសាច់ញាតិមួយចំនួនទៀត បានបន្តការសាងសង់អាស្រមនេះ។*

*សិលាចារឹក K.216 មានពីរផ្ទាំង និងមានកាលបរិច្ឆេទផ្សេងគ្នាដែរ។ ផ្ទាំងទី១សរសេរជាភាសាខ្មែរ មាន១៩បន្ទាត់ ឆ្នាំ ៩២៧ស.ក (១០០៥គ.ស) និង៩២៩ស.ក (១០០៧គ.ស) និយាយពីការថ្វាយស្មោករបស់មេទ័ព (ក្មោងពល) ជូនដល់ព្រះបាទជ័យវីរវរ្ម័ន និងការធ្វើ*

[២] E. Lunet de Lajonquière 1911:418

[៣] E. Aymonier 1900:319

[៤] G. Cœdès 1951:34-44

ចំណាំនៃដង្វាយរបស់ស្ដេចជូនដល់ទេពនៅ គីរីបុរៈ។ សិលាចារឹកផ្ទាំងទី២មាន៥១បន្ទាត់ ដែលបន្ទាត់ទី១ដល់ទី២៥ជាភាសាសំស្ក្រឹត និងពីទី២៦ដល់៥១ ជាភាសាខ្មែរ។ អត្ថបទទាំង២និយាយអំពីការធ្វើដង្វាយជាទាសាទាសី ដីធ្លី និងវត្ថុផ្សេងៗដល់ទេពនៅ សិវបាទ ក្នុងតំបន់ឬក្រុង គីរីបុរៈ ក្នុងឆ្នាំ៩២៨ស.ក (១០០៦គ.ស) គឺក្នុងរាជ្យព្រះបាទជ័យវីរវរ្ម័ន (១០០១គ.សដល់១០១០គ.ស)។

ដូចចនេះ កាលបរិច្ឆេទនៃការសាងសង់ប្រាសាទនេះគឺអាចចាប់ផ្ដើមក្នុងឆ្នាំ៩៣៨ នៃគ្រឹស្តសករាជ ដោយបុគ្គលឈ្មោះ **លោញ អប** និងបន្តសាងសង់ម្តងទៀតក្នុងឆ្នាំ ៩៤៩ នៃគ្រឹស្តសករាជ ដោយក្មួយស្រីខាងម្តាយរបស់បុគ្គលឈ្មោះ **លោញ អប** នោះ។ ប៉ុន្តែយើងមិនដឹងថាមានមូលហេតុអ្វីទេ បានជាប្រាសាទនេះនៅតែមិនបានធ្វើរួចរាល់ជាស្ថាពរ។ រហូតមកដល់រាជ្យស្តេចក្រោយៗ ក៏ពុំមានការស្ថាបនាបញ្ចប់ដែរ គឺគ្រាន់តែការមកធ្វើចំណាំ និងដង្វាយដល់ទីអាស្រមនេះ(ប្រាសាទ)ប៉ុណ្ណោះ។

**អំពីឈ្មោះដើមរបស់ភ្នំ និងប្រាសាទ**

ព្រះនេត្រព្រះជាឈ្មោះថ្មី ដែលយើងមិនដឹងពីប្រភពដើមថាលេចឡើងនៅពេលណា និងដោយសារនរណាជាអ្នកផ្តើមហៅដែរ ប៉ុន្តែឈ្មោះនេះអាចត្រូវបានហៅនៅពេលខ្មែរទទួលនូវរបត់ពុទ្ធសាសនាថេរវាទ ឬក្រោយសម័យអង្គរ។ តាមសិលាចារឹក K.216 បានបង្ហាញថា ភ្នំនេះដើមឡើយមានឈ្មោះហៅថា គីរីបុរៈ។ ចំណែកឯប្រាសាទវិញ គឺជាអាស្រមដែលគេសាងឧទ្ទិសដល់ទេពព្រះឥសូរ។ ក្នុងអត្ថបទសិលាចារឹក ផ្ទាំងទី២ដែលមាន៥១បន្ទាត់ បានបង្ហាញពីឈ្មោះទេពដែលគេគោរពនិងធ្វើដង្វាយនៅគីរីបុរៈនេះ ហៅថា **សិវបាទ (កម្រតេង ជគត សិវបាទ**[៥]**)**។ យើងមិនទាន់ដឹងច្បាស់ថា ពាក្យ **សិវបាទ**នេះ ជាឈ្មោះរបស់ប្រាសាទនេះដែរ ឬត្រឹមជាឈ្មោះរបស់ទេពដែលគេតម្កល់នៅទីនោះ។ ពាក្យ **សិវបាទ**នេះមានច្រើននៅក្នុងសិលាចារឹកដទៃទៀត ហើយត្រូវបានស្នើរឡើងដំបូងដោយលោកសឺដេសថា ពាក្យសិវបាទដែលរកឃើញក្នុងសិលាចារឹកទាំងប៉ុន្មាន ប្រហែលជាឈ្មោះប្រាសាទភ្នំសណ្តូក (កំពង់ធំ)។ អ្នកស្រី ពៅ សាវរស់បានលើកឡើងថា ពាក្យ**សិវបាទ**

[៥] G. Cœdès 1951:42

អាចជាឈ្មោះទីកន្លែងផ្សេងគ្នា។[៦] ថ្មីៗនេះ លោក វង់ សុធារ៉ា បានសិក្សាពីសិលាចារឹកប្រាសាទភ្នំព្រះនេត្រព្រះនេះ ហើយបានបកស្រាយថា **សិវបាទ** គឺជាឈ្មោះប្រាសាទភ្នំព្រះនេត្រព្រះនេះ។

យ៉ាងណាមិញ ចំនុចនេះយើងនិងលើកមកវែកញែកក្នុងអត្ថបទក្រោយ ស្ដីអំពីនាមស័ព្ទ សិវបាទក្នុងសិលាចារឹកបុរាណខ្មែរ។

ជាសង្ខេប យើងអាចដឹងថា ប្រាសាទនេះជាប្រាសាទមួយដែលត្រូវបានកសាងឡើងដោយរាស្ត្រសាមញ្ញ (លោញ អប) និងគ្រួសាររបស់គាត់ គឺមិនមែនដោយមន្ត្រីធំ ឬស្ដេចទេ។ វាជាប្រាសាទមួយដែលមានសិលាចារឹកបញ្ជាក់យ៉ាងច្បាស់លាស់អំពីឆ្នាំនៃការសាងសង់ (៩៣៨គ.ស) និងការសាងសង់បន្ត។ ប៉ុន្តែការងារសាងសង់នេះមិនត្រូវបានបញ្ចប់ជាស្ថាពរទេ។ ក្រោយមកទៀត មន្ត្រីដែលស្ថិតនៅក្រោមព្រះបាទជ័យវីរវរ្ម័នបានមកទូលសុំ និងធ្វើជង្វាយផ្សេងៗ មានទាំងមនុស្ស ដីស្រែ និងវត្ថុដល់អាស្រមនេះ។

## ឯកសារយោង

E. Lunet de Lajonquière.
1911. *Inventaire Descriptif des Monuments du Cambdoge*, Tome III, PEFEO, Paris.
E. Aymonier.
1900. *Le Cambodge: Les Provinces Siamoises*, Tome II, Paris.
G. Cœdès.
1951. *Inscription du Cambodge*, Volume III, Paris.
Savaros Pou.
1992. *An Old Khmer-French-English Dictionary*, Cedoreck, Paris.

[៦] Savaros Pou 1992:531




រូបលេខ១១៖ ប្លង់ប្រាសាទ (Lajonquière (1911:418))



រូបលេខ១២៖ ស៊ុំទ្វាររបស់អគារ (C) ធ្វើមិនទាន់រួច

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា



រូបលេខ៣៖ ផ្តេរធ្វើមិនទាន់រួច



រូបលេខ៤៖ សិលាចារឹក K.215 លើសុំទ្វារខាងត្បូងអគារ (B)

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា